ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៩១ សណន.កសក

# សេចក្តីណែនាំ
## ស្តីពី
## ការបង្កើតនិងពង្រឹងបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្ម

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីបង្កើនផលិតកម្មស្បៀងអាហារ អង្ករ ត្រី សាច់សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក និងបម្រើឱ្យការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ពិសេសក្នុងបរិបទជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតនៅទូទាំងសកលលោក។ ជាលទ្ធផល ផលិតកម្មកសិកម្មទាំងស្បៀងអាហារ និងមិនមែនស្បៀងអាហារ មានការកើនឡើងគួរឱ្យកត់សម្គាល់ ហើយប្រជាកសិករមួយចំនួនកំពុងជួបបញ្ហាទីផ្សារលក់ផលិតផលទាំងនោះ។ ដើម្បីជួយដោះស្រាយបញ្ហាទាំងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយកកម្មវិធី ប្រធានអង្គភាពក្រោមឱវាទក្រសួង និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ឱ្យអនុវត្តជាបន្ទាន់នូវវិធានការចាំបាច់មួយចំនួនបន្ថែមទៀតដូចខាងក្រោម៖

១. ត្រូវរៀបចំបង្កើតបន្ថែមនូវបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្ម ឱ្យបានកាន់តែច្រើនឡើងថែមទៀត ក្នុងន័យបង្កើនបានពេញលេញនូវសមត្ថភាពផ្គត់ផ្គង់ ជាពិសេសបង្កើននូវសមត្ថភាពចរចាថ្លៃជាមួយអ្នកប្រមូលទិញផលិតផលកសិកម្ម ដែលវិធានការនេះនឹងលើកទឹកចិត្តប្រជាកសិករឱ្យធ្វើការដាំដុះដំណាំស្បៀង ការចិញ្ចឹមសត្វ និងវារីវប្បកម្មកាន់តែសកម្ម និងមិនមានការព្រួយបារម្ភអំពីបញ្ហាទីផ្សារ។

២. ត្រូវខិតខំបន្តទៀតនូវផែនការផលិតរបស់ក្រុមបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្មឱ្យផលិតស្របទៅតាមតម្រូវការ និងពេលវេលាដែលត្រូវចុះទៅប្រមូលទិញរបស់ក្រុមហ៊ុន ឬអ្នកប្រមូលទិញផលិតផលកសិកម្ម ដែលអាចជៀសវាងបាននូវការផលិតជន់ជោរ និងមិនមានទីផ្សារច្បាស់លាស់។

៣. ត្រូវសហការឱ្យបានល្អប្រសើរជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីរៀបចំបង្កើត និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងក្រុមបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្ម សំដៅផ្គត់ផ្គង់ស្បៀងអាហារ អង្ករ ត្រី សាច់ ប្រកបដោយភាពជឿជាក់ និងមានប្រសិទ្ធភាព។

៤. ត្រូវរៀបចំបង្កើតផ្សារកសិករ ឬទីតាំងសមស្របណាមួយ ដែលអាចឱ្យកសិករយកផលិតផលសុវត្ថិភាពមកតាំងលក់ ដើម្បីរួមចំណែកដោះស្រាយបញ្ហាទីផ្សារ ធានាបាននូវការផ្គត់ផ្គង់ និងរក្សាបានតុល្យភាពតម្លៃទីផ្សារ។

៥. ត្រូវពិចារណាធ្វើហិរញ្ញប្បទាន និងបណ្តុះបណ្តាលណែនាំផ្សព្វផ្សាយបច្ចេកទេសឱ្យបានសកម្មដល់ក្រុមបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្មដើម្បីពង្រឹងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់។

៦. ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រួលដល់ក្រុមបណ្តុំអាជីវកម្មកសិកម្ម ក្រុមកសិករផលិត និងសហគមន៍កសិកម្ម ឱ្យទទួលបានឥណទានមានអត្រាការប្រាក់ទាបសមរម្យពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មប្រកបដោយភាពអនុគ្រោះ។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

៧. រដ្ឋបាលជលផលត្រូវពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយនូវសំណើសុំនាំចូលផល ផលិតផលជលផលពីបរទេស ដោយមិនត្រូវអនុញ្ញាតឱ្យនាំចូលនូវផល ផលិតផលជលផលដែលមានការប្រកួតប្រជែងខ្លាំងជាមួយផល ផលិតផលវារីវប្បកម្មក្នុងស្រុក។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជានាយកកម្មវិធី អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវសហការឱ្យបានល្អជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធ អនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត
- អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ